## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥

ថ្ងៃពុធ ១៤រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋានរាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន*

ថ្ងៃនេះខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយបំផុតដែលបានដឹកនាំ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥**”។ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិនិងអន្តរជាតិទាំងអស់ ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី២ សម្រាប់ឆ្នាំ២០២៥ នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ពន្ធ័ទាំងអស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការប្រកបដោយផ្លែផ្កាជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការជំរុញនិងចូលរួមអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងលិខិតលេខ ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ការចូលរួមយ៉ាងសកម្ម និងប្រកបដោយថាមពលរបស់យើងទាំងអស់គ្នាក្នុងការឆ្លើយតបនេះ គឺជាសក្ខីកម្មនៃកិច្ចខិតខំប្រឹងប្រែងរួម ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ យើងពិតជាមានមោទនភាពចំពោះវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលដ៏ជោគជ័យដែលកម្ពុជាសម្រេចបានកន្លងមក ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមការដឹកនាំ ការគ្រប់គ្រង និងការសម្របសម្រួលពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

គោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការវិស័យសុខាភិបាល តាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០២៥-២០៣៤ នាពេលថ្មីៗនេះ ក៏បានផ្តល់នូវសិទ្ធិ និងការទទួលខុសត្រូវពេញលេញដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការគ្រប់គ្រងមុខងារនិងធនធានសុខាភិបាលរបស់ខ្លួន ដើម្បីជានាការឆ្លើយតបជាពហុវិស័យប្រកបដោយចីរភាពចំពោះការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា។

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ គឺជាមគ្គុទ្ទេសក៍តម្រង់ផ្លូវសម្រាប់អនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្តេជ្ញាចិត្តបញ្ចប់ជំងឺអេដស៍ជាការគំរាមកំហែងដល់សុខភាពសាធារណៈ ឆ្ពោះទៅសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល ដូចបានកំណត់ក្នុងផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជាឆ្នាំ២០២៤-២០៣៥ ដែលប្រកាសឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤។

ហូតមកដល់ពេលនេះ ក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលមានកម្មវត្ថុចំនួន៣ គោលដៅគោលនយោបាយចំនួន៧ និងវិធានការគោលនយោបាយចំនួន៥៣ ជាលទ្ធផលបានបង្ហាញថា នៅថ្នាក់ជាតិមានក្រសួង ស្ថាប័នចំនួន៣០ បានធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងនោះក្រសួង ស្ថាប័នចំនួន២៥បានរៀបចំ និងបញ្ចូលផែនការសកម្មភាពនិងថវិកាឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងផែនការស្នូលរបស់ក្រសួង ស្ថាប័នខ្លួន ដែលក្នុងនោះមានចំនួន១៥ បានទទួលការអនុម័តថវិកាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅថ្នាក់ក្រោមជាតិ គ្រប់រាជធានី ខេត្តបានបង្កើត ឬបានធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងបានរៀបចំផែនការសកម្មភាពនិងថវិកាឆ្លើយតបនឹងមេរោគអេដស៍បញ្ចូលក្នុងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្នុងឆ្នាំ២០២៤ ព្រមទាំងទទួលបានការគាំទ្រថវិកាសម្រាប់អនុវត្តផែនការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងនោះ លើគោលដៅ៩៥-៩៥-៩៥ កម្ពុជាបានសម្រេច ៩២-១០០-៩៨។ ជាមួយគ្នានេះមានអ្នកផ្ទុកមេរោគអេដស៍ចំនួន៧៥% បានទទួលប័ណ្ណសមធម៌

សុខាភិបាល និងគ្មានរបាយការណ៍ផ្លូវការស្តីពីការរើសអើង និងមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ឡើយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ពីរ៖ ទី១ គឺដើម្បីពិនិត្យ និងវាយតម្លៃរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពនៃការងារប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់រយៈពេល៦ខែចុងឆ្នាំ២០២៥។ ទី២ គឺដើម្បីប្រមូលយោបល់ និងពិភាក្សារកជាតុចូល តាមរយៈការចូលរួមដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននាពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនពីរ រួមមាន៖

ទី១-បទបង្ហាញស្តីពី **«សេចក្តីព្រាងស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៥»** បង្ហាញជូនដោយឯកឧត្តមបណ្ឌិត **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២-បទបង្ហាញស្តីពី **«និយាមប្រតិបត្តិស្តីពីការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ និងការកសាងផែនការប្រតិបត្តិរួម សម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ»** បង្ហាញជូនដោយឯកឧត្តមវេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាចុងក្រោយ កិច្ចប្រជុំពេញអង្គនឹងធ្វើការពិភាក្សា និងអនុម័តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៥ សម្រាប់អនុវត្តបន្តនៅឆមាសទី១ ឆ្នាំ២០២៦។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ក្នុងរយៈពេលប្រាំមួយខែកន្លងទៅនេះ សកម្មភាពរបស់យើងបានផ្តោតលើចីរភាពរចនាសម្ព័ន្ធ និងវិមជ្ឈការ ក្នុងនោះ៖

- យើងកំពុងបញ្ចប់ផែនទីបង្ហាញផ្លូវចីរភាព និងការសិក្សាចំណាយសម្រាប់ការឆ្លើយតបដែលដឹកនាំដោយសហគមន៍ ដើម្បីធានាបាននូវហិរញ្ញវត្ថុប្រកបដោយចីរភាព។
- ក្រសួងសុខាភិបាលកំពុងបង្កើតនិយាមប្រតិបត្តិ(SOP) សម្រាប់ការចុះកិច្ចសន្យាសង្គម និងផែនការអន្តរកាលនិងចីរភាពឆ្លើយតបនឹងជំងឺអេដស៍ ជំងឺរបេងរួមគ្នា។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំនូវ និយាមប្រតិបត្តិស្តីពីការធ្វើវិមជ្ឈការក្នុងការជំរុញការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក និងឃុំសង្កាត់) ដោយពន្លឿនការផ្តល់ការឆ្លើយតបនឹងមេរោគអេដស៍នៅមូលដ្ឋាន។

- ឃុំ សង្កាត់ចំនួន៣២៤ បានដាក់បញ្ចូលការឆ្លើយតបនឹងជំងឺអេដស៍ទៅក្នុងផែនការឃុំ សង្កាត់របស់ខ្លួន ដោយបានប្រមូលថវិកាប្រមាណ៥៨៧ ០០០ដុល្លារអាម៉េរិក។

នៅក្នុងរយៈពេល៦ខែខាងមុខ នៅថ្នាក់ជាតិ យើងនឹងបញ្ចប់ និងអនុវត្តយន្តការជាយុទ្ធសាស្ត្រសំខាន់ៗរួមមាន៖

- បញ្ចប់ការពិនិត្យឡើងវិញនូវផែនទីបង្ហាញផ្លូវប្រកបដោយចីរភាព ដើម្បីកំណត់អត្តសញ្ញាណច្បាស់លាស់ និងដោះស្រាយគម្លាត។
- បញ្ចប់ការសិក្សាការចំណាយដែលគាំទ្រដោយអង្គការUNAIDS ស្តីពីការផ្តល់ហិរញ្ញប្បទានប្រកបដោយសុវត្ថិភាពក្នុងការឆ្លើយតបរបស់សហគមន៍ ដើម្បីបញ្ចូលសេវាកម្មទាំងនេះទៅក្នុងកញ្ចប់មេរោគអេដស៍ស្នូល។
- បង្កើតយន្តការសេវាកម្មបន្តដោយបញ្ចប់ការរៀបចំនិយាមប្រតិបត្តិសម្រាប់កិច្ចសន្យាសង្គមនិងផែនការអន្តរកាលជំងឺអេដស៍ ជំងឺរបេងរួមគ្នា។
- ដាក់បញ្ចូលមេរោគអេដស៍ទៅក្នុងយុទ្ធសាស្ត្រសុខាភិបាល ដោយធានាឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រសុខាភីបាលទី៤(HSP4) ឆ្នាំ២០២៥-២០៣៤ ដែលទើបអនុម័តថ្មី។

ចំណែកឯនៅថ្នាក់ក្រោមជាតិ អាទិភាពស្នូលផ្តោតលើប្រតិបត្តិការយុទ្ធសាស្ត្រវិមជ្ឈការថ្មីរួមមាន៖

- ដាក់ចេញនូវនិយាមប្រតិបត្តិស្តីពីការធ្វើវិមជ្ឈការក្នុងការជំរុញការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ( ខេត្ត ស្រុក និងឃុំ សង្កាត់ )។
- ពង្រឹងគណនេយ្យភាពសង្គមដោយបន្តដាក់បញ្ចូលក្របខ័ណ្ឌគណនេយ្យភាពសង្គម ទៅក្នុងអភិបាលកិច្ចមូលដ្ឋាន។
- បង្កើនសមាហរណកម្មថវិកាមូលដ្ឋានដោយផ្តោតលើការរួមបញ្ចូលគ្នាប្រកបដោយជោគជ័យនូវការឆ្លើយតបនឹងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ផែនការវិនិយោគឃុំ នៅក្នុងតំបន់ដែលនៅសេសសល់។

ជារួម កម្ពុជារក្សាបាននូវមោទនភាពនិងក្តីសង្ឃឹមខ្ពស់ក្នុងការបញ្ចប់ជំងឺអេដស៍ ហើយការប្តេជ្ញាចិត្តនេះ ត្រូវបានអនុវត្តតាមរយៈការពង្រឹងភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងការសម្របសម្រួលសហការជាចរន្តជាតិតែមួយ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីពង្រីកសកម្មភាពឆ្លើយតបទ្វេដង។ ទន្ទឹមនឹងនេះ យើងក៏នឹងពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃជាតិ ដើម្បីធានាបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយ រក្សាបាននូវចីរភាពនៃការឆ្លើយតបជាពហុវិស័យ ពីគ្រប់ស្ថាប័ន ជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន ជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍ ហើយយើងបង្កើតបាននូវស្ថាប័នដឹកនាំគ្រប់គ្រងនិងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាពិសេសមានផែនការយុទ្ធសាស្ត្រជាតិតែមួយ មានប្រព័ន្ធតាមដាននិងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ខ្ញុំមានជំនឿយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ នឹងផ្តល់នូវធាតុចូលបន្ថែមទៀតដល់ក្រុមការងារបច្ចេកទេស សម្រាប់យកទៅបន្តអនុវត្តការងារឆ្លើយតបទៅនឹងការឆ្លងរាលដាលមេរោគអេដស៍និងជំងឺអេដស៍នៅពេលខាងមុខ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនសម្រាប់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ព្រមទាំងបទពិសោធន៍ការងារពីបណ្តាសមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះ និងសូមប្រសិទ្ធពរជ័យជូនឯកឧត្តម លោកជំទាវ លោកលោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងពលំមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យតាមកម្មវត្ថុដែលបានគ្រោងទុក។

ខ្ញុំសូមប្រកាសបើក “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥**” ចាប់ពីពេលនេះតទៅ។

សូមអរគុណ។